រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

041KH01A-01

ការប្រៀនប្រដៅក្នុងក្រុមជំនុំ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៥១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ប្រើការសិក្សានេះ ដើម្បីធ្វើអោយអ្នក និង ក្រុមជំនុំរបស់អ្នកកាន់តែមានភាពបរិសុទ្ធ ។

មានភាពបរិសុទ្ធបានន័យថា បែរចេញពីអំពើបាបគ្រប់យ៉ាង ហើយថ្វាយខ្លួនទាំងស្រុងដើម្បីបំរើ និង ស្រឡាញ់ព្រះជាម្ចាស់ ។ ដើម្បីអាចមានភាពបរិសុទ្ធបាន យើងត្រូវអប់រំ (គ្រប់គ្រងលើ)ខ្លួនឯងដោយរបៀបច្រើនយ៉ាង ។

តើ «ការប្រៀនប្រដៅ» មានន័យដូចម្តេច ? ។ ប្រហែលជាអ្នកគិតថា ជាការកែតម្រង់ ដែលត្រូវធ្វើចំពោះមនុស្សប្រមឹក និងមនុស្សប្រព្រឹត្តកាមគុណថោកទាប ។ ប៉ុន្តែ ការប្រៀនប្រដៅមិនត្រឹមតែកែតម្រង់មនុស្សដែលប្រព្រឹត្តខុសប៉ុណ្ណោះទេ គឺថែមទាំងនាំអោយមនុស្សចេះគោរពចុះចូលចំពោះព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីអោយព្រះអង្គអាចដឹកនាំជីវិតពួកគេ ស្របទៅតាមសេចក្តីបង្គាប់របស់ព្រះអម្ចាស់ផងដែរ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កំណត់ចំណាំ :

សាវ័កដ៏ស្មោះត្រង់របស់ព្រះយេស៊ូគ្រីស្ត

សាវ័ករបស់ព្រះយេស៊ូធ្វើតាមគំរូរបស់ព្រះអង្គ និង ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះអង្គ ។ សាវ័កចេះធ្វើអំណោយ និង ជាក់ជង្វាយដប់ភាគរយ ដោយចិត្តសប្បុរស ហើយចេះផ្សាយដំណឹងល្អ ។ សាវ័កមិនគិតតែប្រយោជន៍ផ្ទាល់ខ្លួន និង មិនចេះនិយាយដើមគេ ។ សាវ័កចេះជួយអ្នកខ្វះខាត អធិស្ឋាន និង រិះគិតអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។ សាវ័កតែងតែទូលសូមអោយព្រះវិញ្ញាណដ៏វិសុទ្ធដឹកនាំជារៀងរាល់ថ្ងៃ ។



សាវ័កមិនត្រឹមតែ « សំរេចចិត្តទទួល » ព្រះគ្រីស្តប៉ុណ្ណោះទេ គឺថែមទាំងប្រតិបត្តិតាមព្រះអម្ចាស់ដែរ ហើយមិនត្រឹមតែសិក្សាព្រះគម្ពីរប៉ុណ្ណោះទេ តែយកសេចក្តីបង្រៀនរបស់ព្រះគម្ពីរមកអនុវត្តក្នុងជីវិត និង ក្នុងកិច្ចការបំរើព្រះជាម្ចាស់របស់ខ្លួនទៀតផង ។

ព្រះគ្រីស្តបង្គាប់យើងអោយ :

☐ បង្កើតនិស្សិតសាលាព្រះគម្ពីរ ។

☐ បង្កើតសាវ័កដែលចេះប្រតិបត្តិតាមព្រះអម្ចាស់ ។

☐ ធ្វើការសំរេចផ្សេងៗ តាមអារម្មណ៍របស់ខ្លួន ។

នៅក្នុង ម៉ាថាយ ២៨:១៩-២០ ព្រះអម្ចាស់យេស៊ូគ្រីស្តបង្គាប់យើងអោយបង្កើត_____ដែលប្រតិបត្តិតាមសេចក្តីបង្គាប់គ្រប់យ៉ាងរបស់ព្រះអង្គ ។

កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- ជួយក្រុមជំនុំអ្នក អោយអាចអនុវត្តដំណាក់ការនៃការអប់រំទាំងអស់នេះ ។

កំណត់ចំណាំ :



© Project WorldReach © SEAN

សាវ័កដ៏ស្មោះត្រង់ មិនមែនត្រឹមតែ «ទទួល» ព្រះគ្រីស្ត និងជឿដំណឹងល្អប៉ុណ្ណោះទេ គឺថែមទាំងប្រព្រឹត្តអំពើល្អបរិសុទ្ធ ដោយជំនឿទៀតផង ។ ចរិតលក្ខណៈរបស់សាវ័កជាផលផ្លែនៃព្រះ-វិញ្ញាណដ៏មានឫទ្ធានុភាពរបស់ព្រះជាម្ចាស់ (កាឡាទី ៥:២២-២៣) ។ ជំនឿបែបនេះ នាំយើងឱ្យចេះទុកចិត្តលើព្រះជាម្ចាស់ក្នុងគ្រប់កិច្ចការ ។ ឧទាហរណ៍ យើងទុកចិត្តថា ព្រះជាម្ចាស់ :

- លើកលែងទោសអំពើបាបទាំងស្រុង និង ប្រទានជីវិតអស់កល្ប (យ៉ូហាន ៣:១៦, ១ យ៉ូហាន ១:៧-១០) ។
- ប្រោសអោយបានវិសុទ្ធ (១ ពេត្រុស ២:៩) ។
- ប្រទានទ្ធានុភាពឱ្យអាចឈ្នះលើសេចក្តីល្បួង និង វិញ្ញាណអាក្រក់ (ម៉ាថាយ ១៧:១៤-២០) ។
- ប្រោសអោយបានជាសះស្បើយពីជំងឺខាងរូបកាយ (ម៉ាថាយ ៩:២៨-២៩, ១៥:២៨, ២ កូរិនថូស ១២:៨-៩)
- ផ្គត់ផ្គង់សំលៀកបំពាក់ ទីជំរក និង ចំណីអាហារ (ម៉ាថាយ ៦:២៥-៣៤) ។
- ជីកនាំការរស់នៅប្រចាំថ្ងៃរបស់យើង (រ៉ូម ៨:១៤) ។

ត្រូវកែតំរូវមនុស្សដែលមានកំហុសខាងក្រោមនេះ :

- បញ្ហារវាងសមាជិក (ម៉ាថាយ ១៨:១៥-១៧, ១ កូរិនថូស ៦:៥-៦) ។
- ការបែកបាក់គ្នា (ទីតុស ៣:១០-១១, រ៉ូម ១៦:១៧-១៨) ។
- ការមិនព្រមធ្វើការងារ (ការចំណាយពេលឥតប្រយោជន៍) (២ ថេស្សាឡូនិក ៣:៧-១៥) ។
- អំពើអសីលធម៌ (១ កូរិនថូស ៥:១-២) ។
- ការលោភលន់ (១ កូរិនថូស ៥:១១) ។
- ការគោរពព្រះក្លែងក្លាយ (១ កូរិនថូស ៥:១១) ។
- ការនិយាយដើមគេ (១ កូរិនថូស ៥:១១) ។
- ការប្រមឹកស្រា (១ កូរិនថូស ៥:១១) ។
- ការលួច (១ កូរិនថូស ៥:១១) ។
- សមាជិកក្នុងក្រុមជំនុំតែមួយ ប្តឹងគ្នាទៅតុលាការ (១ កូរិនថូស ៦:១-១០) ។
- សេចក្តីបង្រៀនក្លែងក្លាយ (រ៉ូម ១៦:១៧) ។

© Project WorldReach © SEAN

នៅពេលដែលអ្នកជឿនោះកែប្រែចិត្តគំនិត គាត់ត្រូវសងរបស់ទ្រព្យ ដែលគាត់បានលួច ឬ សងបំណុលដែលមិនទាន់សង ឬ សូមទោសអស់អ្នកណាដែលគាត់បាននិយាយផ្តេសផ្តាសអំពីពួកគេ នៅពេលដែលគាត់អាចធ្វើបាន (លូកា ១៩:៨) ។ គាត់អាចធ្វើកិច្ចការនេះស្ងាត់ៗ ឬ នៅចំពោះមុខគេឯង ស្របទៅតាមកាលៈទេសៈ ។ ក្រោយដែលគាត់បានកែប្រែចិត្តគំនិតដូចនេះហើយ ក្រុមជំនុំនឹងចាត់ទុកគាត់ជាសមាជិកវិញ ។

ព្រះគម្ពីរមិនបានចែងថា ត្រូវបញ្ឈប់សមាជិកដែលមានកំហុសមិនអោយមកចូលរួមក្នុងក្រុមជំនុំក្នុងរយៈពេលប៉ុន្មាននោះទេ (ឧទាហរណ៍ បីខែ ។ល។) ។ យើងត្រូវប្រុងប្រយ័ត្នចំពោះការនេះ ។ បើមានអ្នកណាម្នាក់បានកែប្រែចិត្តគំនិត ហើយយើងមើលឃើញថា គេកែប្រែចិត្តគំនិតពិតមែន យើងត្រូវទទួលគេជាសមាជិកវិញភ្លាម (២ កូរិនថូស ២:៦-៨) ។

ប៉ុន្តែ ចំពោះអ្នកដឹកនាំដែលបានកសាងខ្លួនឡើងវិញក្រោយពីបានធ្លាក់ល្បែង យើងមិនទាន់អោយគាត់អធិប្បាយ ក្នុងរយៈពេលសមគួរមួយ ដើម្បីកុំអោយដំណឹងល្អខូចកិត្តិយស ។

ព្រះយេស៊ូបានត្រាស់ហៅអ្នកនេសាទត្រីពីរនាក់ គឺលោកពេត្រុស និង លោកអន់ដ្រេ ។ អ្នកទាំងពីរស្តាប់បង្គាប់ព្រះយេស៊ូ ដោយជំនឿ ។ ការដែលពួកគេទុកសំណាញ់ និង ទូកចោល ដើម្បីដើរតាមព្រះអង្គ ធ្វើជាសាវ័ករបស់ព្រះអង្គ ជាភស្តុតាងបង្ហាញពីជំនឿនោះ (ម៉ាថាយ ៤:១៨-២០) ។



ដូចគ្នានេះដែរ ដោយសារជំនឿ យើងក៏លះបង់ការងារ និងសម្ភារៈទាំងឡាយណា ដែលរាំងស្ទះមិនអោយយើងប្រតិបត្តិតាមព្រះអម្ចាស់ដែរ ។

តើអ្នកចង់រស់នៅដោយជំនឿក្នុងព្រះជាម្ចាស់ មិនមែនដើម្បីសម្ភារៈនៅក្នុងលោកីយ៍ ដែលជាបណ្តោះអាសន្នដែរឬទេ ? ។

ការចេះអប់រំ(គ្រប់គ្រងលើ)ខ្លួនឯង

ការចេះទប់ចិត្តខ្លួនឯង ជាផ្នែកសំខាន់មួយរបស់ភាពបរិសុទ្ធ ។ (កាឡាទី ៥:២៣, ២ ធីម៉ូថេ ១:៧) ។



ប្អូនជុន ការប្រៀនប្រដៅនេះ មានគោលបំណងប្អូន :

- ផ្សះផ្សាអោយប្អូនបានជានានឹងព្រះជាម្ចាស់វិញ ហើយធ្វើឱ្យមានមេត្រីភាពក្នុងក្រុមជំនុំឡើងវិញ (កាឡាទី ៦:១) ។
- ជំរះសំអាតក្រុមជំនុំ ព្រោះបើមិនកែតំរូវអំពើបាបណាមួយទេ នឹងមានឥទ្ធិពលអាក្រក់លើមនុស្សគ្រប់គ្នា (១ កូរិនថូស ៥:៦) ។
- ព្រមានអ្នកឯទៀតអំពីគ្រោះថ្នាក់បណ្តាលមកពី « មាត់គ្មានគំរប » ដើម្បីអោយពួកគេដឹងខ្លួន (១ ធីម៉ូថេ ៥:១៩-២០, យ៉ាកុប ៣:១-១២) ។
- ទុកអោយព្រះជាម្ចាស់វិនិច្ឆ័យប្អូនទៅចុះ (១ កូរិនថូស ៥:១២-១៣, ហេប្រឺ ១០:៣០-៣១) ។

ប្អូនជុន ការដែលយើងចាំបាច់ត្រូវធ្វើដូចនេះចំពោះប្អូន នាំអោយយើងពិបាកចិត្តណាស់ ។ ប៉ុន្តែ យើងត្រូវតែប្រតិបត្តិតាមព្រះសូរសៀងរបស់ព្រះជាម្ចាស់ ហើយសុំអោយប្អូនឈប់មកក្រុមជំនុំតទៅទៀត ។ ប្អូនលែងមានឋានៈជាអ្នកជំនួយទៀតហើយ ។ ក្រុមជំនុំបានសំរេចដូចនេះជាឯកច្ឆ័ន្ទ ។ យើងនៅតែបន្តអធិស្ឋានអោយប្អូនកែប្រែចិត្តគំនិត ហើយថ្វាយសិរីល្អទៅព្រះយេស៊ូគ្រីស្តក្នុងជីវិតប្អូនជាថ្មីទៀត ។

នៅពេលដែលប្អូនផ្លាស់ប្តូរចរិយាមារយាទ យើងនឹងរៀបចំកសាងប្អូនជាសមាជិកវិញ ហើយទទួលប្អូនដោយអំណរ ។

ហត្ថលេខារបស់គណៈកម្មាធិការរបស់ក្រុមជំនុំ :

ឧទាហរណ៍អំពីសំបុត្រប្រៀនប្រដៅមួយ :

ថ្ងៃទី ២០ ខែមករា

ជូនចំពោះប្អូនជុន

ប្អូនជុន !

យើងសូមជំរាបសួរប្អូនក្នុងព្រះនាមព្រះអម្ចាស់ ដោយសេចក្តីស្រឡាញ់ និងសូមអោយព្រះជាម្ចាស់ប្រទានពរដល់ប្អូន និងក្រុមគ្រួសាររបស់ប្អូន ។

ប្អូនជុន ព្រះគម្ពីរសញ្ញាថ្មីបង្គាប់យើង ឱ្យកែតំរូវអ្នកដែលមិនកែប្រែចិត្តគំនិតពីកំហុសដ៏ធ្ងន់ធ្ងរ (១ កូរិនថូស ៥:១-១១) ។

ពាក្យនិយាយដើម និង ពាក្យទិតៀនដែលគ្មានការពិតរបស់ប្អូន ចំពោះសមាជិកឯទៀត បានធ្វើអោយមានការបាក់បែកគួរអោយបារម្ភ ។ ខ្ញុំបានដាស់តឿនប្អូនតែពីរនាក់ម្តងហើយ រួចក្រោយមក អ្នកចាស់ទុំប្រៀនប្រដៅប្អូនទៀតដែរ ។ តែដោយប្អូននៅតែមិនព្រមស្តាប់ យើងបានសុំឱ្យក្រុមជំនុំដោះស្រាយបញ្ហានេះ ។ ក្រុមជំនុំបានយល់ព្រមតាមការស្នើសុំរបស់ពួកអ្នកចាស់ទុំ ដែលសុំអោយប្អូនចាកចេញពីក្រុមជំនុំរហូតទាល់តែប្អូនកែប្រែចិត្តគំនិតវិញ ។ ការសំរេចនេះអនុវត្តតែចំពោះប្អូនម្នាក់ប៉ុណ្ណោះ មិនមានទាក់ទងនឹងសមាជិកផ្សេងទៀតនៃក្រុមគ្រួសាររបស់ប្អូនទេ ។

លោកប៉ូលបង្គាប់លោកធីម៉ូថេថា÷ *«តែត្រូវហាត់គោរពប្រណិប័តន៍ព្រះជាម្ចាស់វិញ »* (១ ធីម៉ូថេ ៤:៧) ។ ត្រូវគ្រប់គ្រងលើខ្លួនឯង ជាប់ជាប្រចាំ ! ព្រះអម្ចាស់បង្គាប់យើងថា÷ *«អ្នករាល់គ្នាត្រូវតែវិសុទ្ធ ព្រោះយើងវិសុទ្ធ »* (១ ពេត្រុស ១:១៥-១៦) ។

ព្រះជាម្ចាស់ប្រោសយើងអោយបានវិសុទ្ធ ដោយកែប្រែយើងបន្តិចម្តងៗ ទៅតាមលក្ខណៈរបស់ព្រះគ្រីស្ត ។



យើងមានគំរូឥតខ្ចោះអំពីភាពបរិសុទ្ធ ក្នុងព្រះយេស៊ូគ្រីស្ត ។ យើងអាចកាន់តែស្គាល់ដឹងអំពីព្រះយេស៊ូគ្រីស្ត ដោយអធិស្ឋានជាប់ជាប្រចាំ និង រស់នៅតាមគំរូរបស់ព្រះអង្គរាល់ពេល ។ យើងត្រូវមានសេចក្តីស្រឡាញ់ ត្រូវចេះបន្ទាបខ្លួន និង មានជំនឿដូចព្រះ-អង្គ ។

នៅពេលដែលព្រះយេស៊ូត្រូវអារក្សល្បួង ព្រះអង្គបានទប់ទល់នឹងវា (ម៉ាថាយ ៤:១-១១) ។ យើងក៏មានព្រះវិញ្ញាណរបស់ព្រះ-យេស៊ូសំរាប់តទល់នឹងអារក្សដែរ ។ ព្រះយេស៊ូបង្កើតផលផ្លែជាភាពបរិសុទ្ធក្នុងយើង តាមរយៈជំនឿរបស់យើង (កាឡាទី ៣:២-៥) ។

«ដូច្នេះ មិនមែនខ្ញុំទៀតទេ ដែលរស់ គឺព្រះគ្រីស្តទេតើ ដែលមានព្រះជន្មរស់នៅក្នុងខ្ញុំ...» ។

(កាឡាទី ២:២០)

បើសិនជាអ្នកជឿមានកំហុសនោះ មិនយកចិត្តទុកដាក់ស្តាប់អ្នកណាម្នាក់ ឬក៏មិនស្តាប់ក្រុមជំនុំទាំងមូល គេត្រូវប្រាប់អ្នកជឿនោះតាមបែបបទត្រឹមត្រូវអំពីការសំរេចដែលបានអនុម័ត ។

បើសិនជាអ្នកដឹកនាំក្រុមជំនុំមានកំហុស ក៏គេធ្វើដូចគ្នានេះដែរ ។





គ្រូគង្វាល ឬ អ្នកចាស់ទុំរបស់ក្រុមជំនុំ មិនត្រូវកែតម្រង់សមាជិកមានកំហុស តែម្នាក់ឯងទេ ។ បើធ្វើដូចនេះ អាចនាំអោយគេមានការអាក់អន់ចិត្តចំពោះគ្រូគង្វាល ។ នេះជាមូលហេតុដែលនាំឱ្យកាឡាទី ៦:១ ប្រាប់យើងអោយប្រយ័ត្នប្រយែងយកអ្នកជឿចាស់ទុំផ្សេងទៀតទៅជាមួយអ្នក ពេលអ្នកកែតម្រង់អ្នកជឿម្នាក់ ដែលបានធ្វើខុស ។

ត្រូវធ្វើតាមជំហាននៃការកែតម្រង់ ទី ១ និង ទី ២ សិន ។ បើអ្នកដែលមានកំហុសមិនព្រមកែប្រែចិត្តគំនិត ក្រុមជំនុំត្រូវសំរេចធ្វើការប្រៀនប្រដៅចុងក្រោយបង្អស់ ។



នៅពេលដែលយើងរួមក្នុងព្រះគ្រីស្ត ព្រះវិញ្ញាណដ៏វិសុទ្ធនឹងធ្វើអោយយើងមានភាពបរិសុទ្ធ

នៅក្នុងវគ្គគម្ពីរ ដែលដកស្រង់ពី កាឡាទី ៥:២២-២៥ ខាងក្រោមនេះ សូមគូសពីក្រោមសេចក្តីប្រាំបួនយ៉ាង ដែលជាផលផ្លែ ដែលព្រះវិញ្ញាណដ៏វិសុទ្ធបង្កើតក្នុងយើង :

«រីឯផលដែលកើតមកពីព្រះវិញ្ញាណវិញ គឺសេចក្តីស្រឡាញ់ អំណរ សេចក្តីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្តោស មេត្តាជំនឿ ចិត្តស្លូតបូត ចេះទប់ចិត្តខ្លួនឯង ។ គ្មានវិន័យណាជំទាស់នឹងសេចក្តីទាំងនេះទេ ។ អស់អ្នកដែលរួមជាមួយព្រះគ្រីស្តយេស៊ូ សុទ្ធតែបានឆ្កាងតណ្ហា និង បំណងលោភលន់ផ្សេងៗរបស់លោកីយ៍នោះចោលហើយ ។ ប្រសិនបើយើងមានជីវិតដោយសារព្រះ-វិញ្ញាណមែន យើងក៏ត្រូវប្រតិបត្តិតាមព្រះវិញ្ញាណដែរ » ។

ទីបី :

«ប្រសិនបើគាត់មិនព្រមស្តាប់ពាក្យអ្នកទាំងនោះ ត្រូវនាំរឿងនេះទៅប្រាប់ក្រុមជំនុំ /ព្រះសហគមន៍ ហើយបើគាត់នៅតែមិនព្រមក្រុមជំនុំ/ព្រះសហគមន៍ ត្រូវចាត់ទុកគាត់ដូចជាសាសន៍ដទៃ...» ។

យោលទៅតាមម៉ាថាយ ១៨:១៧ និង ១ ធីម៉ូថេ ៥:២០ បើសិនជាអ្នកនោះនៅតែបន្តធ្វើខុសទៀត ត្រូវអោយក្រុមជំនុំដោះស្រាយរឿងនេះ ។ បើសិនជាអ្នកនោះមិនព្រមស្តាប់ក្រុមជំនុំទៀត ត្រូវដេញគាត់ចេញពីក្រុមជំនុំ រហូតដល់គាត់ព្រមកែប្រែចិត្តគំនិត ។

សូមសរសេរជំហានទាំងបី សំរាប់កែតម្រង់បងប្អូនរួមជំនឿ :

១- _____

_____

២- _____

_____

៣- _____

_____

© Project WorldReach © SEAN

ជំហានសំរាប់កែតម្រង់អ្នកឈ្មើ ដែលមានកំហុស

(ម៉ាថាយ ១៨:១៥-១៨)

ទីមួយ :

«ប្រសិនបើមានបងប្អូនណាម្នាក់បានប្រព្រឹត្តអំពើបាបអ្វីមួយ ចូរទៅជួបអ្នកនោះស្ងាត់ៗតែពីរនាក់ ហើយស្តីប្រដៅគាត់ទៅ ។ បើគាត់ស្តាប់អ្នក អ្នកនឹងរក្សាបងប្អូននោះ មិនឱ្យបាត់ឡើយ » ។

សូមកុំស្តាប់ពាក្យចោទប្រកាន់ ប្រសិនបើអ្នកចោទគេ មិនបានទៅនិយាយផ្ទាល់ជាមួយអ្នកជាប់ចោទជាមុនសិនទេ ។

ទីពីរ :

«តែបើគាត់មិនព្រមស្តាប់អ្នកទេ ចូរនាំម្នាក់ ឬ ពីរនាក់ទៀតទៅជាមួយជួយដាស់តឿន ដើម្បីសំរួលរឿងទាំងអស់ ដោយមានសាក្សីពីរ ឬ បីនាក់ » ។ យើងត្រូវដោះស្រាយជាមួយគេ ដោយសំរួល និង កែតម្រង់ពួកគេ ដោយចិត្តស្លូតបូត ស្របទៅតាម កាឡាទី ៦:១ ។

ខព្រះគម្ពីរទាំងប៉ុន្មានខាងក្រោមនេះ ដកស្រង់ពី ម៉ាថាយ

សូមគូសពីក្រោមតំរិយាបថប្រាំបីយ៉ាង ដែលជាចរិតលក្ខណៈរបស់គ្រីស្តជន ដែលពោរពេញដោយព្រះវិញ្ញាណរបស់ព្រះគ្រីស្ត ។

«អ្នកណាជាក់ចិត្តជាអ្នកក្រខ្សត់ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេបានទទួលព្រះរាជ្យនៃស្ថានបរមសុខ !

អ្នកណាសោកសៅ អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសំរាលទុក្ខពួកគេ !

អ្នកណាមានចិត្តស្លូតបូត អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងទទួលផែនដីទុកជាមតិក !

អ្នកណាស្រេកឃ្លានសេចក្តីសុចរិត អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងប្រទានអោយពួកគេបានឆ្អែត !

អ្នកណាមានចិត្តមេត្តាករុណា អ្នកនោះមានសុភមង្គលហើយ ដ្បិតព្រះជាម្ចាស់នឹងសំដែងព្រះហឫទ័យមេត្តាករុណាដល់ពួកគេវិញ !

អ្នកណាមានចិត្តបរិសុទ្ធ អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងឃើញព្រះជាម្ចាស់ !

អ្នកណាកសាងសន្តិភាព អ្នកនោះមានសុភមង្គលហើយ ដ្បិតពួកគេនឹងមានឈ្មោះជាបុត្ររបស់ព្រះជាម្ចាស់ !

អ្នកណាត្រូវគេបៀតបៀន ព្រោះតែបានធ្វើតាមសេចក្តីសុចរិត អ្នកនោះមានសុភមង្គលហើយ ដ្បិតគេបានទទួលក្នុងព្រះរាជ្យនៃស្ថានបរមសុខ ! » ។

ភាពបរិសុទ្ធជាសេចក្តីស្រឡាញ់ឆេះឆួលចំពោះព្រះជាម្ចាស់ ដែលនាំអោយយើងធ្វើអ្វីៗ ដែលមានប្រយោជន៍ នាំអោយយើងមានគុណសម្បត្តិគ្រប់យ៉ាង នាំអោយយើងធ្វើការល្អ និង នាំអោយយើងបានវិសុទ្ធ (១ កូរិនថូស ១៣:១-៣, កាឡាទី ៥:២២-២៣, ភីលីព ២:១៣) ។

យើងមិនមែនកែតម្រង់មនុស្សដែលប្រព្រឹត្តអំពើបាប ដើម្បីដាក់ទណ្ឌកម្មគេនោះទេ គឺព្រះជាម្ចាស់ជាអ្នកដាក់ទោស មិនមែនយើងទេ (ហេប្រឺ ១០:៣០-៣១, ១២:៥-១១) ។



© Project WorldReach © SEAN

តើក្រុមជំនុំរបស់អ្នកធ្វើពិធីកាច់នំប៉័ង នៅពេលណាខ្លះ ? ។

ក្រុមជំនុំដំបូងរបស់ពួកសាវក ធ្វើពិធីកាច់នំប៉័ងនៅថ្ងៃអាទិត្យ (កិច្ចការ ២០:៧) ។ ការធ្វើពិធីនេះនៅថ្ងៃអាទិត្យ មិនមែនជាសេចក្តីបង្គាប់ទេ ប៉ុន្តែ បើក្រុមជំនុំមិនស្ងួរយកចិត្តទុកដាក់ធ្វើពិធីកាច់នំប៉័ង ក្រុមជំនុំនោះ នឹងមិនស្ងួរបានទទួលព្រះពរទេ ។

យើងចូលរួមធ្វើពិធីកាច់នំប៉័ង ដោយទឹកចិត្តគោរព និង អំណរ ។ យើងប្រើតុស្អាតមួយ ។ នំប៉័ង និង ទឹកទំពាំងបាយជូរ អាចគ្របដោយក្រណាត់ស្អាត ។

ការកែតម្រង់អ្នកដែលមិនស្តាប់បង្គាប់

«អ្នករាល់គ្នាត្រូវតែវិសុទ្ធ ព្រោះយើងវិសុទ្ធ » ។

(១ ពេត្រុស ១:១៦)

យើងកែតម្រង់ពួកអ្នកដែលធ្លាក់ចុះក្នុងអំពើបាប ដើម្បីជួយកសាងពួកគេឡើងវិញ (កាឡាទី ៦:១) និង ធ្វើអោយក្រុមជំនុំបានវិសុទ្ធ (១ កូរិនថូស ៥:១-៥) ។

យើងមិនត្រូវប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃទេ (២ កូរិនថូស ១០:១២) ។ ផ្ទុយទៅវិញ ត្រូវប្រៀបធៀបខ្លួនឯងជាមួយព្រះគ្រីស្ត (អេភេសូ ៤:១៣) ។ ភាពបរិសុទ្ធមិនមែនគ្រាន់តែលះបង់ទម្លាប់អាក្រក់ និង អំពើបាបដែលមើលឃើញជាក់ស្តែងប៉ុណ្ណោះទេ គឺត្រូវសំអាតចិត្តអោយលែងមានអំនួត ការលោភលន់ ការច្រណែន ឈ្នានីស គំនុំ ការចង់បានទ្រព្យរបស់គេ ។ល។ ដែលមាននៅក្នុងចិត្ត ។ យើងអាចទូលសូមព្រះជាម្ចាស់អោយបំពេញយើងដោយសេចក្តីស្រឡាញ់របស់ព្រះយេស៊ូគ្រីស្ត និងផលផ្លែរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបណ្តេញអំពើបាបលាក់កំបាំងទាំងនេះចេញពីចិត្តយើងអោយអស់ ។



បើសិនជាខ្លួនយើងធ្វើបាបតាមរយៈពាក្យសំដី និង ចិត្តគំនិតរបស់យើងនោះ តើយើងហ៊ានទិតៀនអ្នកជឿឯទៀត ដោយសារគេមានអំពើបាបជាក់ស្តែងដែរឬទេ ? ។ ការដែលយើងចង្អុលអំពីអំពើបាបរបស់អ្នកដទៃ ធ្វើអោយយើងមានអារម្មណ៍ថា យើងបរិសុទ្ធជាងគេឬ ? ។

ព្រះយេស៊ូបានបង្គាប់ថា៖

«កុំថ្កោលទោសអ្នកដទៃអោយសោះ ដើម្បីកុំអោយព្រះជាម្ចាស់ថ្កោលទោសអ្នករាល់គ្នា បើអ្នករាល់គ្នាថ្កោលទោសគេយ៉ាងណា ព្រះជាម្ចាស់ក៏នឹងថ្កោលទោសអ្នករាល់គ្នាយ៉ាងនោះដែរ ។ ព្រះអង្គនឹងវាល់អោយអ្នករាល់គ្នាតាមរង្វាល់ ដែលអ្នករាល់គ្នាវាល់ឱ្យអ្នកដទៃ ។ ហេតុអ្វីបានជាអ្នកមើលឃើញល្អងធូលី នៅក្នុងភ្នែកបងប្អូន តែមើលមិនឃើញធ្នឹម នៅក្នុងភ្នែករបស់អ្នកផ្ទាល់នេះ ? » ។

(ម៉ាថាយ ៧:១-៣)



តើគេធ្វើពិធីកាច់នំប៉័ងបានត្រឹមត្រូវដែរឬទេ ?

☐ ត្រឹមត្រូវ ។

☐ មិនត្រឹមត្រូវទេ ។

យើងត្រូវពិនិត្យពិច័យមើលចិត្តគំនិតរបស់យើងសិនមុននឹងចូលរួមធ្វើពិធីកាច់នំប៉័ង ។ បើយើងចូលរួមដោយមិនបានរៀបចំចិត្តគំនិត នោះព្រះជាម្ចាស់នឹងដាក់ទោសយើង ។ យើងត្រូវអធិស្ឋានក្នុងចិត្តដើម្បីលន់តួសារភាពអំពើបាបរបស់យើង ទូលថ្វាយទៅព្រះបិតារបស់យើង ដែលគង់នៅស្ថានបរមសុខ (១ កូរិនថូស ១១:២៧-៣២) ។



© Project WorldReach © SEAN

តើនៅក្នុងពេលថ្វាយបង្គំ មានគិតគូររៀបចំអោយកុមារអាចចូលរួម ដោយមានសណ្តាប់ធ្នាប់ ឬ អាចទទួលការហាត់រៀន ស្របតាមអាយុរបស់ពួកគេដែរឬទេ ?

☐ មាន ។

☐ គ្មានទេ ។



តើព្រះវិញ្ញាណដ៏វិសុទ្ធធ្វើឱ្យយើងបរិសុទ្ធ ដោយរបៀបណា ? ។ ព្រះអង្គប្រទានអោយយើងមានឫទ្ធានុភាព ដើម្បីអោយយើងអាចប្រតិបត្តិតាមព្រះយេស៊ូ គឺ« *ខំប្រឹងធ្វើការទាំងគោរពកោតខ្លាច និងញាប់ញ័រ ស្របតាមការសង្គ្រោះដែលបងប្អូនបានទទួល* » ។

(ភីលីព ២:១២)

យើងត្រូវការហាត់ពត់លត់ជំខ្លួនឯងរាល់ថ្ងៃ ដោយអធិស្ឋាន និងរិះគិតអំពីព្រះគម្ពីរ ដើម្បីអាចប្រតិបត្តិតាមព្រះគ្រីស្ត ។ នេះជារបៀបដែលព្រះវិញ្ញាណដ៏វិសុទ្ធប្រទានអោយយើងមានឫទ្ធានុភាពសំរាប់ធ្វើកិច្ចការទាំងអស់នេះ ។

« *ប្រសិនបើអ្នកណាម្នាក់នៅរួមជាមួយព្រះគ្រីស្ត អ្នកនោះបានកើតជាថ្មី អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ* » ។

(២ កូរិនថូស ៥:១៧)

តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ យើងបានឆ្ពោងសម្លាប់បំណងអាក្រក់ទាំងឡាយ (រ៉ូម ៨:១២-១៣, កាឡាទី ៥:១៦-២៤) ។

ព្រះយេស៊ូមានបន្ទូលថា÷ *«បើអ្នកណាចង់មកតាមក្រោយខ្ញុំ ត្រូវលះបង់ខ្លួនឯងចោល ត្រូវលីឈើឆ្កាងរបស់ខ្លួនរៀងរាល់ថ្ងៃ ហើយមកតាមខ្ញុំចុះ »* (លូកា ៩:២៣) ។

លះបង់ខ្លួនឯងចោល ? ។ លីឈើឆ្កាងរបស់ខ្លួនរាល់ថ្ងៃ ? ។ យើងអាចធ្វើដូចនេះបាន លុះត្រាតែយើងជាអ្នកដើរតាមព្រះយេស៊ូគ្រីស្ត ។ សិស្សរបស់ព្រះយេស៊ូតែងតែប្រុងប្រៀបខ្លួនរងទុក្ខលំបាកដើម្បីព្រះអម្ចាស់របស់ពួកគេ និង ស្លាប់ដើម្បីជំនឿរបស់គេ ។

ព្រះជាម្ចាស់ប្រទានកម្លាំងអោយយើងអាចធ្វើដូចនេះបាន : *«..ព្រះជាម្ចាស់ទេតើ ដែលធ្វើអោយបងប្អូនមានទាំងបំណង មានទាំងសមត្ថភាព អាចនឹងប្រព្រឹត្តតាមព្រះបំណងដ៏សប្បុរសរបស់ព្រះអង្គ »* ។

(ភីលីព ២:១៣)

ព្រះយេស៊ូតែងតែភ្ញាក់ពីព្រលឹមដើម្បីអធិស្ឋាន ។ នៅពេលដែលព្រះអង្គអធិស្ឋាន តែងតែមានហេតុការណ៍ធំៗកើតឡើង ។

តើអ្នកអធិស្ឋានម្នាក់ឯង ព្រមទាំងអធិស្ឋានជាមួយក្រុមគ្រួសាររបស់អ្នក ជារៀងរាល់ថ្ងៃដែរឬទេ ? ។ _____

តើផ្នែកផ្សេងទៀតនៃការថ្វាយបង្គំត្រូវបានរៀបចំ ស្របទៅតាមប្រធានបទរបស់ការថ្វាយបង្គំដែរឬទេ ? (ការអានព្រះគម្ពីរ បទចំរៀងសរសើរតម្កើង ទីបន្ទាល់ ។ល។) ។

☐ ស្រប ។

☐ មិនស្របទេ ។

តើអ្នកជឹកនាំមកទាន់ពេលដែរឬទេ ?

☐ ទាន់ ។

☐ មិនទាន់ ។

ការមកយឺត ជាការលួចពេលវេលារបស់អ្នកដទៃ ហើយមិនលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ទេ ។ បើសិនជាអ្នកជឹកនាំមកយឺត អ្នកឯទៀតនឹងមើលស្រាលចំពោះការថ្វាយបង្គំ ។

«ត្រូវចេះប្រើប្រាស់ពេលវេលា ដ្បិតសម័យនេះអាក្រក់ណាស់ ។ ហេតុនេះ មិនត្រូវធ្វើជាមនុស្សឥតគំនិតឡើយ តែត្រូវរិះគិតអោយយល់ព្រះហឫទ័យរបស់ព្រះអម្ចាស់ » ។

(អេភេសូ ៥:១៦-១៧)

តើអ្នកចំណាយពេលប៉ុន្មាន ដើម្បីរៀបចំសេចក្តីអធិប្បាយ ?

☐ ខ្ញុំនឹកឃើញពីសេចក្តីដែលខ្ញុំត្រូវអធិប្បាយ ក្នុងពេលថ្វាយ-បង្គំតែម្តង ។

☐ ខ្ញុំរៀបចំការអធិប្បាយយ៉ាងឆាប់រហ័ស មុនពេលថ្វាយបង្គំ ។

☐ ខ្ញុំចំណាយពេលច្រើនម៉ោងដើម្បីអធិស្ឋាន រិះគិតពិចារណា និង រៀបចំយូរថ្ងៃ មុនពេលថ្វាយបង្គំ ។

ការដែលសមាជិកអធិស្ឋាន អានព្រះគម្ពីរ និង ច្រៀងសរសើរតម្កើងព្រះជាម្ចាស់ នោះប្រសើរជាងស្តាប់សេចក្តីអធិប្បាយឥតខ្ចីមសារដែលគ្រូអធិប្បាយមិនបានរៀបចំអោយបានត្រឹមត្រូវ ។

តើអ្នកដឹកនាំថ្វាយបង្គំ តែងតែជ្រើសរើសបទចំរៀងសរសើរតម្កើងដោយហ្មត់ចត់ មុនពេលថ្វាយបង្គំដែរឬទេ ?

☐ បានជ្រើសរើស ។

☐ មិនបានជ្រើសរើសមុនដោយហ្មត់ចត់ទេ ។

រប្យែបសំខាន់ៗដែលនាំអោយបានវិសុទ្ធ

ពេលដែលអ្នករិះគិតអំពីព្រះបន្ទូលព្រះជាម្ចាស់ប្រចាំថ្ងៃ ត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមព្រះជាម្ចាស់ ក្នុងគ្រប់កិច្ចការនៅថ្ងៃនោះ រួចធ្វើតាមការសំរេចនោះទៅ ! (ម៉ាថាយ ៤:៤) ។

- ទុកអោយព្រះជាម្ចាស់រំដោះអ្នកអោយរួចពីសេចក្តីល្បួង និង កែប្រែអ្នកតាមរយៈការអធិស្ឋាន ដែលជាការប្រកបជាមួយព្រះជាម្ចាស់ (លូកា ២១:៣៦, ២២:៤០, ២ កូរិនថូស ៣:១៧) ។
- ប្រតិបត្តិតាមព្រះយេស៊ូ នៅពេលកំពុងមានបញ្ហា និង មានទុក្ខលំបាកផ្សេងៗ (១ ពេត្រុស ១:៧) ។

ការអប់រំនៅក្នុងក្រុមគ្រួសារ

គ្រូគង្វាលរបស់ក្រុមជំនុំ ត្រូវជួយអោយឪពុកម្តាយចេះឃ្វាលក្រុមគ្រួសារខ្លួន ។

ព្រះជាម្ចាស់បានបង្គាប់ថា បុរសត្រូវមានភរិយាតែមួយ ហើយត្រូវស្រឡាញ់នាង ។ គ្រីស្តជនត្រូវទិតៀនអោយមានសេចក្តីសុខសាន្ត និង មានអំណរក្នុងក្រុមគ្រួសារ រៀងៗខ្លួន (អេភេសូ ៥:២១-៣៣, កូឡូស ៣:១៨-១៩, ១ ធីម៉ូថេ ៣:៤-៥, ទីតុស ២:៤-៥) ។



«សូមបងប្អូនទាំងអស់គ្នាលើកតម្កៃការរស់នៅជាស្វាមីភរិយា គឺមិនត្រូវក្បត់ចិត្តគ្នាឡើយ ដ្បិតព្រះជាម្ចាស់នឹងវិនិច្ឆ័យទោសអ្នកប្រព្រឹត្តអំពើប្រាសចាកសីលធម៌ និង ផិតក្បត់ » ។

(ហេប្រឺ ១៣:៤)

សណ្តាប់ធ្នាប់របស់ការប្រជុំថ្វាយបង្គំ

តើការថ្វាយបង្គំរបៀបណា ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់ ? ។

ការថ្វាយបង្គំដែលរៀបចំបានល្អ មានគោលដៅ មានលេងបទភ្លេងសមរម្យ ដែលនាំអោយមនុស្សចូលទៅក្នុងវត្តមានរបស់ព្រះជាម្ចាស់ មានធ្វើពិធីកាច់នំបុ័ង ដោយមានការលន់តួសារភាពអំពើបាប និង សេចក្តីអធិប្បាយ ដែលរៀបចំបានល្អ និង ជួយកសាងជំនឿរបស់ក្រុមជំនុំ សុទ្ធតែគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។



តើអ្នកមានអធិស្ឋានទូលសូមអោយព្រះអម្ចាស់ចាក់ប្រេងតាំងប្រទានឫទ្ធានុភាពដល់ការថ្វាយបង្គំដែរឬទេ ? ។ _____

បើសិនជាប្រាក់ដង្វាយ មិនគ្រប់គ្រាន់សំរាប់ការចាយវាយតាម
គំរោងថវិកាទេ ហេរញ្ញិក :

- ☐ មិនត្រូវផ្ញើប្រាក់ទៅផ្គត់ផ្គង់គ្រីស្តទូតទេ ។
- ☐ មិនត្រូវអោយប្រាក់ខែគ្រូគង្វាលទេ ។
- ☐ ចែកចាយប្រាក់អោយសមរម្យ ទៅតាមលទ្ធភាពដល់អ្នក ដែលត្រូវទទួល ហើយជូនដំណឹងអំពីការខ្វះខាតទៅអ្នកដឹកនាំក្រុមជំនុំ ។

ចំលើយ : ហេរញ្ញិកចែកចាយប្រាក់ដែលមាន ស្របទៅតាម
គោលដៅ និង ថវិការបស់ក្រុមជំនុំ ។

បើសិនជាប្រាក់ចំណូលបានច្រើនលើសពីការប៉ាន់ស្មានក្នុងគំរោង
ថវិកា ហេរញ្ញិកត្រូវ :

- ☐ ជូនប្រាក់លើសនោះទៅគ្រូគង្វាល ។
- ☐ ទុកអោយអ្នកដឹកនាំក្រុមជំនុំសំរេចប្រើប្រាស់ប្រាក់លើសនោះ ។
- ☐ អោយប្រាក់ដែលលើសនោះ ទៅឪពុកក្មេកខ្ចី ។

ចំលើយ : ហេរញ្ញិកត្រូវរក្សាប្រាក់លើសទុកអោយអ្នកដឹកនាំ
ក្រុមជំនុំសំរេច អំពីការប្រើប្រាស់ប្រាក់នោះ ។

នៅក្នុង ១ កូរិនថូស ៧:១-៥ លោកប៉ូលពន្យល់ថា÷

«បងប្អូនបានសរសេរសំបុត្រទៅខ្ញុំថា ប្រសិនបើបុរសមិនប៉ះពាល់ស្ត្រីទេ នោះជាការប្រសើរ ។ ប៉ុន្តែ ដើម្បីចៀសវាងកុំអោយមានការប្រាសចាកសីលធម៌ បុរសម្នាក់ៗត្រូវមានប្រពន្ធ ហើយស្ត្រីម្នាក់ៗ ក៏ត្រូវមានប្តីដែរ ។ ប្តីត្រូវបំពេញករណីយកិច្ចជាប្តីចំពោះប្រពន្ធរបស់ខ្លួន រីឯប្រពន្ធក៏ត្រូវធ្វើដូច្នោះចំពោះប្តីវិញដែរ ។ ប្រពន្ធគ្មានសិទ្ធិអ្វីនឹងប្រើរូបកាយរបស់ខ្លួន តាមអំពើចិត្តទេ ព្រោះរូបកាយនោះជារបស់ប្តី រីឯប្តីវិញ ក៏ដូច្នោះដែរ គេគ្មានសិទ្ធិអ្វីនឹងប្រើរូបកាយរបស់ខ្លួនតាមអំពើចិត្តទេ ព្រោះជារបស់ប្រពន្ធ ។ មិនត្រូវបង្អត់គ្នាទៅវិញទៅមកឡើយ លើកលែងតែបានព្រមព្រៀងគ្នា ដើម្បីទុកពេលមួយរយៈសំរាប់អធិស្ឋានប៉ុណ្ណោះ ។ រួចហើយចូររួមរស់ជាមួយគ្នាដូចធម្មតាវិញទៅ ក្រែងលោមារសាតាំងល្បួងចិត្តបងប្អូន មកពីទ្រាំមិនបាន » ។

យោងទៅតាមសេចក្តីបង្រៀននេះ តើមនុស្សអាចចៀសផុតពីអំពើប្រាសចាកសីលធម៌ ដោយរបៀបណា ? ។ _____

_____

_____



ជញ្ជាំងនៃការមិនយល់ចិត្តគ្នា

ព្រះយេស៊ូដឹកនាំគ្រួសារគ្រីស្តជន ហើយព្រះអង្គជាសិរសារបស់ពួកគេដែរ ។ បើសិនជាប្តីស្រឡាញ់ និង ប្រតិបត្តិតាមព្រះគ្រីស្ត ក្រុមគ្រួសារទាំងមូលនឹងធ្វើតាមគាត់ ។ ព្រះវិញ្ញាណព្រះជាម្ចាស់ជួយយើងអោយអាចធ្វើអោយក្រុមគ្រួសាររបស់យើង មានសេចក្តីសុខ និង អំណរ ។

ការចាត់ចែងថវិកាក្រុមជំនុំ

ការចេះចាត់ចែងថវិកា ជាផ្នែកមួយទៀតនៃការរៀបចំ ។ យើងគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិរបស់ព្រះជាម្ចាស់ ។ អ្វីៗទាំងអស់ដែលយើងមានសុទ្ធតែជារបស់ព្រះជាម្ចាស់ ព្រមទាំងពេលវេលា សមត្ថភាព និង ប្រាក់កាសរបស់យើងផង ។ សមាជិកក្រុមជំនុំទាំងអស់ផ្គត់ផ្គង់ការងាររបស់ព្រះជាម្ចាស់ ដោយដាក់ជង្វាយស្មគ្រចិត្ត និង ជង្វាយដប់ភាគរយ ។

តើនៅក្នុងក្រុមជំនុំអ្នក អ្នកត្រូវរៀបចំកិច្ចការនេះ អោយកាន់តែប្រសើរដែរឬទេ ? ។ _____

តើក្រុមជំនុំអ្នក មានធ្វើគំរោងថវិកាប្រចាំឆ្នាំដែរឬទេ ? ។_____

គំរោងថវិកានេះ គឺជាការប៉ាន់ស្មានអំពីចំណូលរបស់ក្រុមជំនុំ និងជាបញ្ជីចំណាយ ដែលអនុញ្ញាតិអោយហេរញ្ញិកចាយវាយ ។

- អធិស្ឋានសំរាប់អ្នកជឿឯទៀត មិត្តភក្តិ និង សត្រូវ (អេភេសូ ៦:១៨, លូកា ៦:២៨) ។
- ធ្វើការងារ ដើម្បីធ្វើអោយព្រះរាជ្យរបស់ព្រះអម្ចាស់យេស៊ូគ្រីស្តរីកចំរើនឡើង និង ដើម្បីអោយមានសេចក្តីសុខសាន្ត សណ្តាប់ធ្នាប់ និង យុត្តិធម៌នៅក្នុងសហគមន៍ និង ប្រទេស (ម៉ាថាយ ៥:១៣-១៦) ។

មូលហេតុនៃការលុបឈ្មោះពីបញ្ជីសមាជិក

- ការផ្ទេរទៅក្រុមជំនុំផ្សេង (ផ្ញើលិខិតផ្តាំផ្ញើទៅក្រុមជំនុំថ្មី) ។
- ការលែងទទួលស្គាល់ជាសមាជិក (គឺត្រូវបញ្ឈប់សមាជិកដែលមិនកែប្រែចិត្តគំនិតពីបាប មិនអោយចូលរួមក្នុងក្រុមជំនុំទៀតទេ) ។
- ការមិនចូលរួមថ្វាយបង្គំ (លុះត្រាតែមានមូលហេតុត្រឹមត្រូវដូចជាឈឺ ត្រូវធ្វើដំណើរ ឬ មូលហេតុត្រឹមត្រូវផ្សេងទៀត) ។
- មរណៈភាព ។

លេខាត្រូវកែតម្រូវបញ្ជី ដោយទៀងទាត់ ។ តើលេខាមានបានធ្វើដូចនេះទេ ? ។ _____

ក្រុមគ្រួសារដែលមានការអប់រំ និង សណ្តាប់ធ្នាប់នឹងធ្វើអោយសមាជិកក្រុមគ្រួសារបានវិសុទ្ធ ។

ប្តី : ត្រូវគ្រប់គ្រងក្រុមគ្រួសាររបស់ខ្លួនអោយបានល្អ (១ ធីម៉ូថេ ៣:៤-៥) ។

ប្តី : ត្រូវស្រឡាញ់ភរិយារបស់ខ្លួន និង ថែរក្សានាង ដូចថែរក្សាខ្លួនឯងដែរ (អេភេសូ ៥:២៥-៣៣) ។

ប្រពន្ធ : ត្រូវគោរពចុះចូលស្វាមីរបស់ខ្លួន ដូចជាគោរពចុះចូលព្រះជាម្ចាស់ដែរ (អេភេសូ ៥:២២-២៤) ។

ប្តីប្រពន្ធ : ត្រូវស្រឡាញ់គ្នាទៅវិញទៅមក និង គោរពចុះចូលគ្នាទៅវិញទៅមក (អេភេសូ ៥:២១) ។

កូនៗ : ត្រូវស្តាប់បង្គាប់ឪពុកម្តាយរបស់ខ្លួន ដោយស្រឡាញ់ព្រះអម្ចាស់ (អេភេសូ ៦:១-៣) ។

ឪពុកម្តាយ : ត្រូវចិញ្ចឹមកូនដោយស្រឡាញ់ និង អប់រំវា ដោយពាក្យប្រៀនប្រដៅ និង ដំបូន្មានស្របតាមព្រះអម្ចាស់ (អេភេសូ ៦:៤) ។

តើវគ្គព្រះគម្ពីរណាមួយ ដែលបង្រៀនអំពីភារៈកិច្ចរបស់សមាជិកក្រុមគ្រួសារម្នាក់ៗ? ។ សូមរកចំលើយនៅក្នុងព្រះគម្ពីររបស់អ្នក ។

- ១ ធីម៉ូថេ ជំពូក ៤ ។
- អេភេសូ ៥:២១ ដល់ ៦:៤ ។
- ហេប្រឺ ជំពូក ១៣ ។

ប្តីប្រពន្ធដែលឈ្លាសវៃ រៀបចំធ្វើគម្រោងថវិកាសំរាប់ក្រុមគ្រួសារ ។ ការធ្វើគម្រោងថវិកា ជាការគិតគូរគណនាអំពីចំណូល និង ចំណាយ ។

គ្រួសារខ្លះត្រូវបាក់បែកគ្នា ដោយសារពួកគេចាយលុយទៅលើរបស់ដែលមិនចាំបាច់ ឬ ដោយសារប្តីប្រពន្ធមិនបានពិភាក្សាគ្នា និង សួរយោបល់គ្នាទៅវិញទៅមក អំពីការចាយលុយ ។ មួយវិញទៀត បំណុលបំផ្លាញសេចក្តីសុខសាន្តក្នុងក្រុមគ្រួសារ ។

រ៉ូម ១៣:៨ ចែងថា៖ *«មិនត្រូវជំពាក់អ្វីនរណា»* ។ ប្តីប្រពន្ធត្រូវព្រមព្រៀងគ្នាធ្វើគំរោងថវិកាមួយ ។

- ផ្សាយដំណឹងល្អអំពីព្រះគ្រីស្តប្រាប់មិត្តភក្តិ និង អ្នកជិតខាង (កិច្ចការ ១:៨) ។
- ស្តាប់តាមគ្រូគង្វាលរបស់ខ្លួន (១ កូរិនថូស ៩:១២-១៤, ១ ថេស្សាឡូនិក ៥:១២-១៣, ហេប្រឺ ១៣:១៧) ។
- ថ្វាយដង្វាយស្ម័គ្រចិត្ត និង ដង្វាយដប់ភាគរយ ដើម្បីផ្គត់ផ្គង់ការងាររបស់ព្រះជាម្ចាស់ (ម៉ាថាយ ៦:១៩-២១) ។
- ចូលរួមក្នុងកម្មវិធីថ្វាយបង្គំ ព្រមទាំងពិធីកាច់នំប៉័ង (ម៉ាថាយ ២៦:២៦-២៨, ហេប្រឺ ១០:២៥) ។
- ធ្វើកិច្ចការបំរើខ្លះថ្វាយព្រះជាម្ចាស់ (រ៉ូម ១២:៤-៨, អេភេសូ ៤:១១-១៦, ១ កូរិនថូស ១២) ។
- អធិស្ឋាន និង សិក្សាព្រះគម្ពីរជាមួយក្រុមគ្រួសារជាទៀងទាត់ (សុភាសិត ២២:៦) ។
- ទទួលស្វាគមន៍ពួកអ្នកជឿថ្មី ដោយបង្រៀនពួកគេអោយក្លាយជាសាវក ដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត (ម៉ាថាយ ២៨:១៩-២០) ។

© Project WorldReach © SEAN

បញ្ជីសមាជិក

លេខារបស់ក្រុមជំនុំសរសេរឈ្មោះសមាជិកទាំងអស់ ព្រមទាំងពត៌មានខាងក្រោមនេះ សំរាប់សមាជិកម្នាក់ៗ នៅក្នុងសៀវភៅបញ្ជីមួយ :

១- អាស័យដ្ឋាន

២- លេខទូរស័ព្ទ

៣- ថ្ងៃ ខែ ដែលទទួលពិធីជ្រមុជទឹក

៤- ថ្ងៃ ខែ ដែលផ្លាស់មកក្រុមជំនុំ (បើសិនជាមកពីក្រុមជំនុំផ្សេង)

៥- សេចក្តីផ្សេងៗដែលមានប្រយោជន៍ ។

ភារៈកិច្ចរបស់សមាជិក

- ស្រឡាញ់ និង ថ្វាយសិរីល្អទៅព្រះជាម្ចាស់ ដោយថ្វាយជីវិតដាច់ដល់ព្រះអង្គ រក្សាខ្លួនមិនឱ្យសៅហ្មងនៅក្នុងលោកីយ៍ និង ប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះយេស៊ូ (ម៉ាថាយ ២៨:១៨-២០, ១ កូរិនថូស ៦:៩-១១, ២ ពេត្រុស ១:៤-៨) ។

ថវិកាគ្រួសារជា :

☐ ការធ្វើបញ្ជីប៉ាន់ស្មានអំពីប្រាក់ចំណូលដែលអាចរកបាន និង ប្រាក់ចំណាយ ។

☐ ការទស្សន៍ទាយអំពីទ្រព្យសម្បត្តិ ។

បើមានគំរោងថវិកា នោះបានន័យថា យើងចេះគិតគូរអំពីចំណូល និង ចំណាយ ។

ព្រះយេស៊ូមានព្រះបន្ទូលថា÷ *«ក្នុងចំណោមអ្នករាល់គ្នា ប្រសិនបើនរណាម្នាក់ចង់សង់ផ្ទះថ្មធំមួយ អ្នកនោះត្រូវអង្គុយគិតគូរមើលថ្លៃសង់ជាមុនសិន ដើម្បីអោយដឹងថា តើខ្លួនមានប្រាក់លួម នឹងបង្ហើយសំណង់ ឬ យ៉ាងណា »* (លូកា ១៤:២៨) ។

© Project WorldReach © SEAN

ការរៀបចំរបស់ក្រុមជំនុំ/ព្រះសហគមន៍របស់ព្រះគ្រីស្ត

ក្រុមជំនុំដែលមានការរៀបចំល្អ ស្គាល់សមាជិករបស់ខ្លួនទាំង-អស់ ។ ការដែលសមាជិកណាមួយធ្វើជាសមាជិករបស់ក្រុមជំនុំពីរព្រមគ្នា ឬមួយក្រុមជំនុំមិនដឹងថា អ្នកណាខ្លះជាសមាជិកពិតប្រាកដ ដែលបានទទួលពិធីជ្រមុជទឹករួចហើយនោះ ធ្វើឱ្យមានការច្របូកច្របល់ណាស់ ។



លក្ខខ័ណ្ឌសំរាប់សមាជិក

ដើម្បីអាចក្លាយជាសមាជិករបស់ក្រុមជំនុំមួយ ត្រូវមានលក្ខណៈដូចខាងក្រោមនេះ :

- មានជំនឿលើព្រះអម្ចាស់យេស៊ូគ្រីស្តដែលបានសុគត ដើម្បីលើកលែងទោសអំពើបាបរបស់យើង និង មានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានជីវិតអស់កល្បដល់យើង (យ៉ូហាន ៣:១៦, ១៤:៦, ១ យ៉ូហាន ១:៧-៩) ។
- បានកែប្រែចិត្តគំនិត គឺលន់តួសារភាពអំពើបាបទៅព្រះ-ជាម្ចាស់ និង បែរចេញពីអំពើបាប (យ៉ូហាន ៥:១៤, ៨:១១) ។
- ចេះគោរពប្រតិបត្តិតាមព្រះគ្រីស្ត (យ៉ូហាន ១៥:១៤) ។

បើសិនជាអ្នកជឿម្នាក់ ចង់ទៅធ្វើជាសមាជិករបស់ក្រុមជំនុំមួយទៀត ដែលមានជំនឿ និង គោលជំនឿដូចគ្នា អ្នកនោះត្រូវសុំលិខិតផ្តាំផ្ញើពីក្រុមជំនុំមុន ដើម្បីយកទៅអោយក្រុមជំនុំថ្មីនោះ ។